# តើលោកអ្នកជាជនអន្តោប្រវេសន្តឬ? តើលោកអ្នកមានកូនរៀននៅសាលាដែរ ឬទេ?

*កូនរបស់លោកអ្នកអាចនឹងមានលក្ខណៈគ្រប់គ្រាន់ក្នុងការទទួលបានអាហារនៅសាលាដោយឥតគិតប្រាក់ ឬដោយបញ្ចុះតំលៃ ទោះបីជាលោកអ្នក ឬកូនលោកអ្នកមិនមានលិខិតអនុញ្ញាតិអោយរស់នៅក៏ដោយ ។*

*អាហារនៅសាលាក៏ដូចជាការអប់រំរបស់រដ្ឋដែរ គឺផ្តល់ដល់កុមារគ្រប់រូបដោយមិនគិតពីស្ថានភាពអន្តោប្រវេសន្ត!*

  

នេះគឺជាចំលើយមួយចំនួនទៅនឹងសំនួរទូទៅខ្លះៗអំពីអាហារនៅសាលាៈ

1. តើខ្ញុំ ឬកូនរបស់ខ្ញុំត្រូវមាន "ហ្គ្រីនកាត" ដែរឬទេដើម្បីទទួលបានអាហារនៅសាលា? **ទេ!**

2. តើខ្ញុំត្រូវមាន សូសល សេឃ្យូរីធី ណាំបឺ ដែរឬទេ?

   **ទេ** ។ មាតាបិតាមិនតំរូវអោយមាន សូសល សេឃ្យូរីធី ណាំបឺដើម្បីទទួលបានអាហារនៅសាលាទេ ។ ប្រសិនបើលោកអ្នកមិនមាន លោកអ្នកត្រូវគូសក្នុងប្រអប់ដែលដាក់ថា "ខ្ញុំមិនមាន សូសល សេឃ្យូរីធី ណាំបឺទេ" ។

3. តើខ្ញុំអាចនឹងត្រូវគេរាយការណ៍ទៅការិយាល័យអន្តោប្រវេសន្តដែរឬទេ ប្រសិនបើខ្ញុំដាក់ពាក្យសុំអាហារនៅសាលាអោយកូនៗរបស់ខ្ញុំ?

   **ទេ** ។ សាលាមិនរាយការណ៍ពីនរណាម្នាក់ទៅការិយាល័យអន្តោប្រវេសន្តទេ ។ ព័ត៌មាននៅក្នុងបែបបទដាក់ពាក្យសុំរបស់លោកអ្នកគឺជាការសំងាត់ និងមិនអាចចែករំលែកបានទេ ។

4. តើការទទួលបានអាហារនៅសាលានេះនឹងប៉ះពាល់ដល់ការដាក់ពាក្យសុំភាពស្របច្បាប់របស់ខ្ញុំនាពេលអនាគតដែរឬទេ?

   **ទេ** ។ អាហារនៅសាលាក៏ដូចជាប័ណ្ណទិញអាហារដែរ គឺជាអត្ថប្រយោជន៍ដែលមិនមែនជាលុយ ។ ទាំងអស់នេះមិនប៉ះពាល់ដល់ស្ថានភាពអន្តោប្រវេសន្តរបស់លោកអ្នកទេ ប្រសិនបើលោកអ្នកកំពុងដាក់ពាក្យសុំភាពស្របច្បាប់ ឬសុំសញ្ជាតិអាមេរិក ។

5. តើខ្ញុំត្រូវផ្តល់ពតិមានអ្វីខ្លះដល់សាលានៅពេលដែលខ្ញុំដាក់ពាក្យសុំអាហារនៅសាលា?

   បែបបទដាក់ពាក្យសុំ ស្នើអោយលោកអ្នកចុះចំនួនសមាជិកគ្រួសាររបស់លោកអ្នក និងចុះប្រាក់ចំនូលរបស់លោកអ្នក (ចំនូលដែលរកបាន និងចំនូលដែលមិនទទួលកម្រៃនានាដូចជាការចិញ្ចឹមកូន និងភាពអត់ការងារធ្វើ ជាដើម) ។ ជាទូទៅការប្រកាសពីប្រាក់ចំនូលដោយមិនលាក់លៀម គឺជាអ្វីដែលត្រូវបានស្នើសុំអោយធ្វើ ។ ជូនកាលសាលាធ្វើការជ្រើសរើសដោយចៃដន្យនូវករណីជាគំរូ ។ ប្រសិនបើករណីរបស់លោកអ្នកត្រូវបានជ្រើសរើស លោកអ្នកអាចនឹងត្រូវសុំអោយធ្វើការបញ្ជាក់ប្រាក់ចំនូល ។ ការបញ្ជាក់នេះរួមមានសំណៅចុងសន្លឹកនៃប្រាក់ខែ សេចក្តីបញ្ជាក់ពីនិយោជក់ ឬសេចក្តីបញ្ជាក់ដោយមិនលាក់លៀមនៃការធ្វើការអោយខ្លួនឯង ឬបញ្ជាក់ថាលោកអ្នកមិនមានប្រាក់ចំនូល ។

6. តើខ្ញុំអាចទទួលបានពាក្យសុំសំរាប់ទទួលបានអាហារនៅសាលាពីណា?

   ពាក្យសុំមាននៅសាលារបស់កូនលោកអ្នក ឬអាចទទួលបានពីនាយកសេវាកម្មអាហារនៃ ស្គូល ឌីសស្ទ្រីក ។